ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ

*ថ្ងៃ អង្គារ ៨ កើត ខែ ស្រាពណ៍ ឆ្នាំ ជូត ទោស័ក ព.ស ២៥៦៤*
*រាជធានីភ្នំពេញ, ថ្ងៃទី ២៨ ខែ កក្កដា ឆ្នាំ ២០២០*

# សេចក្តីប្រកាសព័ត៌មាន

## កិច្ចប្រជុំគណៈកម្មាធិការគោលនយោបាយសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ស្តីពី "សេចក្តីព្រាងច្បាប់ស្តីពីមូលបត្ររដ្ឋ (ថ្មី)" និង "សេចក្តីព្រាងយុទ្ធសាស្ត្រអភិវឌ្ឍន៍វិស័យកាត់ដេរ ផលិតស្បែកជើង និងកាបូបកម្ពុជា ២០២០-២០២៥"

នាព្រឹកថ្ងៃទី ២៨ ខែ កក្កដា ឆ្នាំ២០២០, នៅទីស្តីការក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ, ឯកឧត្តមអគ្គបណ្ឌិតសភាចារ្យ **អូន ព័ន្ធមុនីរ័ត្ន** ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ និងជាប្រធានគណៈកម្មាធិការគោលនយោបាយសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ (គ.ស.ហ) បានដឹកនាំកិច្ចប្រជុំ គ.ស.ហ ដើម្បីពិនិត្យ និងពិភាក្សាលើរបៀបវារៈសំខាន់ៗចំនួនពីររួមមាន÷ *"សេចក្តីព្រាងច្បាប់ស្តីពីមូលបត្ររដ្ឋ (ថ្មី)"* និង *"សេចក្តីព្រាងយុទ្ធសាស្ត្រអភិវឌ្ឍន៍វិស័យកាត់ដេរ ផលិតស្បែកជើង និងកាបូបកម្ពុជា ២០២០-២០២៥"* ដោយទទួលបានការអញ្ជើញចូលរួមពីថ្នាក់ដឹកនាំជាន់ខ្ពស់ និងមន្ត្រីបច្ចេកទេសរបស់ក្រសួង-ស្ថាប័នពាក់ព័ន្ធ ។

### *១- សេចក្តីព្រាងច្បាប់ស្តីពីមូលបត្ររដ្ឋ (ថ្មី)÷*

ដោយតម្រូវការធនធាន និងហិរញ្ញប្បទានមានការកើនឡើង ដែលអាចឆ្លើយតបនឹងតម្រូវការជាក់ស្តែងនៃការអភិវឌ្ឍសេដ្ឋកិច្ច និងសង្គម, តាមរយៈបុរេសកម្មក្នុងការគិតគូរដើម្បីពង្រីកវិសាលភាពនៃប្រភពហិរញ្ញប្បទាន ជាពិសេសដោយផ្តោតការយកចិត្តទុកដាក់លើប្រភពហិរញ្ញប្បទានក្នុងស្រុកដែលនៅមានសក្តានុពលខ្ពស់នៅឡើយ, ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ បានរៀបចំ *"សេចក្តីព្រាងច្បាប់ស្តីពីមូលបត្ររដ្ឋ (ថ្មី) (Government Securities)"* ដើម្បីជំនួសឱ្យច្បាប់ចាស់ដែលបានចូលជាធរមានតាំងពីឆ្នាំ ២០០៧ ហើយកំពុងមានសុពលភាពរហូតដល់ពេលបច្ចុប្បន្ន ។ *"ច្បាប់មូលបត្ររដ្ឋថ្មី"* នេះ ជាមូលដ្ឋានគតិយុត្ត ដើម្បីអនុញ្ញាតឱ្យរាជរដ្ឋាភិបាលកម្ពុជាអាចបោះផ្សាយមូលបត្រ តាមរយៈការកំណត់នូវវិសាលភាព, ការសម្រេចលើការបោះផ្សាយ, កំណត់ទំហំ និងទំរង់នៃការបោះផ្សាយមូលបត្ររដ្ឋ, ការកំណត់អ្នកចូលរួម និងនីតិវិធីក្នុងការជួញដូរមូលបត្ររដ្ឋ ព្រមទាំងទោសបញ្ញត្តិ ជាដើម ។ *"សេចក្តីព្រាងច្បាប់ថ្មី"* នេះ មានភាពគ្រប់ជ្រុងជ្រោយ និងឆ្លើយតបខ្ពស់ទៅនឹងបរិបទបច្ចុប្បន្ន និងនិន្នាការការប្រែប្រួលនៃការអភិវឌ្ឍរបស់កម្ពុជា តាមរយៈការកំណត់នូវក្របខ័ណ្ឌរួមសម្រាប់គ្រប់គ្រងការបោះផ្សាយ, ការជួញដូរ និងការគ្រប់គ្រងមូលបត្ររដ្ឋ និងមានការកំណត់នូវគោលបំណងជាក់លាក់ រួមមាន÷

១. ការឆ្លើយតបទៅនឹងតម្រូវការហិរញ្ញប្បទាន ជាពិសេសសម្រាប់ការអភិវឌ្ឍហេដ្ឋារចនាសម្ព័ន្ធ,
២. ការពង្រឹងការគ្រប់គ្រងតម្រូវការសាច់ប្រាក់,
៣. ការអភិវឌ្ឍវិស័យមូលបត្រ និងហិរញ្ញវត្ថុ និង
៤. ការគាំទ្រគម្រោងអាទិភាព និងចាំបាច់ផ្សេងទៀត ។

***២- សេចក្តីព្រាងយុទ្ធសាស្ត្រអភិវឌ្ឍន៍វិស័យកាត់ដេរ ផលិតស្បែកជើង និងកាបូបកម្ពុជា ២០២០-២០២៥÷***

វិស័យកាត់ដេរ ផលិតស្បែកជើង និងកាបូប បានដើរតួយ៉ាងសំខាន់ រួមចំណែកយ៉ាងធំដល់ការអភិវឌ្ឍសេដ្ឋកិច្ចកម្ពុជា តាមរយៈ ការបង្កើតការងារ បង្កើនចំណូលដល់ប្រជាពលរដ្ឋ និងកាត់បន្ថយភាពក្រីក្រ ។ ថ្វីត្បិតវិស័យកាត់ដេរ ផលិតស្បែកជើង និងកាបូបត្រូវបានអភិវឌ្ឍជាបន្តបន្ទាប់ ដោយផ្អែកលើភាពខ្លាំងដែលជាឧត្តមភាពប្រកួតប្រជែងកន្លងមក, វិស័យនេះ នៅជួបនឹងបញ្ហាប្រឈមមួយចំនួន ។ រាជរដ្ឋាភិបាលកម្ពុជា បានគិតគូររៀបចំ ***"យុទ្ធសាស្ត្រអភិវឌ្ឍន៍វិស័យកាត់ដេរ ផលិតស្បែកជើង និងកាបូបកម្ពុជា ២០២០-២០២៥"*** ដែលជាផែនទីបង្ហាញផ្លូវដ៏មានសារៈសំខាន់ ដោយនៃយុទ្ធសាស្ត្រនេះបានកំណត់ចក្ខុវិស័យប្រែក្លាយវិស័យកាត់ដេរ ផលិតស្បែកជើង និងកាបូបកម្ពុជា ឱ្យទៅជាឧស្សាហកម្មដែលមានភាពឆ្លើយតប, មានតម្លៃបន្ថែមខ្ពស់, មានមូលដ្ឋានគាំទ្រពិពិធកម្ម និងមានភាពប្រកួតប្រជែង មុនបំណាច់ឆ្នាំ ២០២៥ ហើយដែលវិស័យនេះអាចចូលរួមចំណែកសកម្មក្នុងការអភិវឌ្ឍសង្គម-សេដ្ឋកិច្ចកម្ពុជា ។

***"យុទ្ធសាស្ត្រ"*** នេះមានគោលបំណងកំណត់នូវទិសដៅអភិវឌ្ឍន៍រួម, បង្កើនភាពឯករាជ្យ, ពង្រឹងភាពប៉ាន់ប្រមាណបាន និងស្ថិរភាពនៃវិស័យកាត់ដេរ ផលិតស្បែកជើង និងកាបូបកម្ពុជា ដើម្បីបន្តលើកកម្ពស់ការអភិវឌ្ឍវិស័យនេះប្រកបដោយចីរភាព និងបរិយាប័ន្ន ។ ដើម្បីសម្រេចបាននូវគោលបំណង និងចក្ខុវិស័យ, យុទ្ធសាស្ត្របានកំណត់គោលដៅ÷

១. បន្តពង្រឹងធនធានមនុស្សដើម្បីបង្កើនផលិតភាព និងបង្កើតគន្លងអាជីពសម្រាប់កម្មករ-និយោជិត,
២. បន្តធ្វើឱ្យប្រសើរឡើងនូវលក្ខខណ្ឌការងារ និងសុខុមាលភាពរបស់កម្មករ-និយោជិត,
៣. លើកកម្ពស់ការវិនិយោគក្នុងស្រុក និងអន្តរជាតិដោយផ្តោតលើផលិតផលមានបន្ថែមតម្លៃខ្ពស់,
៤. ទាក់ទាញការវិនិយោគនៅក្នុងឧស្សាហកម្មគាំទ្រវិស័យនេះ និង
៥. ជំរុញការធ្វើពិពិធកម្មទីផ្សារសម្រាប់ការនាំចេញផលិតផលកាត់ដេរ ស្បែកជើង និងកាបូប ។

ឯកឧត្តមអគ្គបណ្ឌិតសភាចារ្យ **អូន ព័ន្ធមុនីរ័ត្ន** ឧបនាយករដ្ឋមន្ត្រី ប្រធានអង្គប្រជុំ បានថ្លែងអំណរគុណ និងវាយតម្លៃខ្ពស់ដល់ក្រុមការងារដែលបានខិតខំរៀបចំឯកសារដ៏មានសារសំខាន់ទាំងពីរខាងលើ និងបានណែនាំឱ្យក្រុមការងារ និងស្នើក្រសួង-ស្ថាប័នពាក់ព័ន្ធបន្តផ្តល់កិច្ចសហការ និងកែសម្រួលឯកសារទាំងពីរនេះតាមស្មារតីនៃអង្គប្រជុំ ដើម្បីឱ្យឯកសារទាំងពីរនេះមានភាពពេញលេញ គ្រប់ជ្រុងជ្រោយ និងអនុវត្ត និងអាចឈានដល់ការបន្តនីតិវិធីគោរពស្នើសុំការអនុម័តពីរាជរដ្ឋាភិបាល ៕